ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

national policies of nursing

# ឯកសារ

# គោលនយោបាយជាតិនៃការថែទាំជំងឺ

ឧបត្ថម្ភដោយៈ

សហប្រតិបត្តិការសុខាភិបាល បារាំង-កម្ពុជា

2005

ក្រសួងសុខាភិបាល
នាយកដ្ឋានមន្ទីរពេទ្យ

MINISTRY OF HEALTH
DEPARTMENT OF HOSPITAL SERVICES

# អារម្ភកថា

លោក លោកស្រីជាទីស្នេហា !

គោលនយោបាយជាតិនៃការថែទាំជំងឺគឺជាកំរងគោលនយោបាយណែនាំដែលអាចជួយអភិវឌ្ឍចំណេះដឹងក្នុងការថែទាំជំងឺដល់ប្រជាពលរដ្ឋកម្ពុជាទូទាំងប្រទេស ។កំរងគោលនយោបាយនេះនឹងបង្ហាញ លោក លោកស្រី អំពីនិយមន័យនៃគោលនយោបាយ កម្មវត្ថុនៃគោលនយោបាយ គោលនយោបាយផ្នែករដ្ឋបាល ការបង្កើនគុណភាពនៃការថែទាំ ការផ្តល់ការថែទាំសមស្របតាមមន្ទីរពេទ្យបង្អែកនិមួយៗ ការបង្កើនការត្រួតពិនិត្យជំងឺឆ្លង អនាម័យនៅក្នុងមន្ទីរពេទ្យ និង ការធ្វើឱ្យមានរចនាសម្ព័ន្ធគិលានុបដ្ឋាក-យិកានិងឆ្មបនៅគ្រប់មន្ទីរពេទ្យបង្អែក ។

កំរងគោលនយោបាយជាតិនៃការថែទាំជំងឺនេះ បានរក្សាទុកនូវគោលបំណងក្នុងការពង្រីកការយល់ដឹងរបស់គិលានុបដ្ឋាក-យិកានិងឆ្មបពីការថែទាំជំងឺ ការព្យាបាលសំរន់ និង ធ្វើឱ្យអនាម័យក្នុងមន្ទីរពេទ្យបង្អែកកាន់តែល្អប្រសើរឡើង ។ទោះបីជាយ៉ាងណាក៏ដោយ ក៏ការិយាល័យគិលានុបដ្ឋាក-យិកានិងឆ្មបនៃនាយកដ្ឋានមន្ទីរពេទ្យបានធ្វើការកែប្រែនូវ ចំណុចសំខាន់ៗមួយចំនួនដើម្បីធ្វើឱ្យកំរងគោលនយោបាយជាតិនេះកាន់តែមានខ្លឹមសារនិងមានប្រយោជន៍ថែមទៀត ។ ឧទាហរណ៍ៈការបន្ថែមឧបសម្ព័ន្ធដែលទាក់ទងទៅ នឹងគោលគំនិតសំខាន់ៗ និង អមទៅដោយក្រដាសគំរូ សំរាប់វាយតំលៃទៀតផង ។

ខ្ញុំសង្ឃឹមថាកំរងគោលនយោបាយជាតិនៃការថែទាំជំងឺនេះនិងក្លាយជាឧបករណ៍មួយដ៏ងាយស្រួលក្នុងការអនុវត្តន៍ការងារថែទាំជំងឺ និង មានប្រយោជន៍សំរាប់គ្រប់គិលានុបដ្ឋាក-យិកានិងឆ្មបទាំងអស់ ។

ក្នុងនាមក្រសួងសុខាភិបាល យើងខ្ញុំមានសេចក្តីសោមនស្សរីករាយជាទីបំផុតហើយជឿជាក់ថា លោក លោកស្រីដែលជាមន្ត្រីសុខាភិបាលទាំងអស់នឹងអនុវត្តតាមគោលនយោបាយនេះដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ការថែទាំជំងឺឱ្យកាន់តែប្រសើរឡើង និង ដើម្បីឱ្យមន្ទីរពេទ្យបង្អែកទូទាំងព្រះរាជាណាចក្រកម្ពុជាមានអនាម័យល្អប្រសើរ ។

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

វេជ្ជ. នូត-សុខុម

## តារាងមាតិកា


អារម្ភកថា ..........................................................................១

តារាងមាតិកា.......................................................................២

បុព្វកថា ..........................................................................

I. គោលនយោបាយ

១. សេចក្តីផ្តើម

២. និយមន័យនៃការថែទាំជំងឺ

II. កម្មវត្ថុនៃគោលនយោបាយ

បង្កើនគុណភាពនៃការថែទាំជំងឺ

១. អនុញ្ញាតដល់ប្រធានគិលានុបដ្ឋាក-យិកា/ឆ្មបនិងនាយអគារឱ្យមានការទទួលខុសត្រូវចំពោះគុណភាពនៃការថែទាំជំងឺ ។

២. អភិវឌ្ឍការអនុវត្តន៍ដែលមានគុណភាពគ្រប់គ្រាន់ចំពោះការថែទាំជំងឺ

៣. ជួយគាំទ្រសំណូមពររបស់ប្រធានថែទាំ

III. គោលនយោបាយប្រតិបត្តិ

ក. ផ្តល់ការថែទាំឱ្យបានសមស្រប៖

១. ធ្វើឱ្យងាយស្រួលក្នុងការត្រិះរិះក្នុងរង្វង់ការងារថែទាំដោយទទួលខុសត្រូវលើអ្នកជំងឺ

២. ជួយរៀបចំសំណុំលិខិតអ្នកជំងឺឱ្យបានសមស្របក្នុងមន្ទីរពេទ្យបង្អែក

៣. ជួយរៀបចំអ្នកជំងឺ និង ក្រុមគ្រួសារឱ្យមានការចូលរួមចំណែកក្នុងការថែទាំជំងឺ

៤. ប្តូរការយល់ដឹង និង ផ្តល់ពត័មានទៅវិញទៅមកទាក់ទងនឹងអ្នកជំងឺ

ខ. បង្កើនការត្រួតពិនិត្យជំងឺឆ្លង

១. លើកកំពស់អនាម័យ និង ការកំចាត់មេរោគនៅក្នុងមន្ទីរពេទ្យ

២. ចល័តក្រុមការងារឱ្យយល់ដឹងពីអនាម័យ

៣. ធ្វើឱ្យអ្នកជំងឺ និង ក្រុមគ្រួសាររបស់គេមានការភ្ញាក់រឭកពីអនាម័យ

## IV. គោលនយោបាយរដ្ឋបាល

រចនាសម្ព័ន្ធសេវាគិលានុបដ្ឋាក-យិកា និង ឆ្មប

១. ជួយចាត់ចែងបង្កើតសេវាគិលានុបដ្ឋាក-យិកា និង ឆ្មបនៅក្នុងមន្ទីរពេទ្យ

២. ធានានូវទំនាក់ទំនងមន្ទីរពេទ្យនានាឱ្យមានការចាត់ចែងថែទាំជំងឺឱ្យបានសមស្រប

៣. ឱ្យតំលៃដល់ប្រធានថែទាំ និង នាយអគារ

## V. ឧបសម្ព័ន្ធ

# បុព្វកថា

ឯកសារនេះគឺជាគោលនយោបាយថ្នាក់ជាតិដែលត្រូវបានទទួលស្គាល់ និង ត្រូវបានអនុវត្តដោយក្រសួងសុខាភិបាលក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើឱ្យសំរេចបាននូវតំរូវការជាមូលដ្ឋាននានាសំរាប់ការថែទាំ ជំងឺ ។

គោលនយោបាយនេះរួមបញ្ចូលយ៉ាងលំអិតលើៈ

- ការបង្កើនគុណភាពនៃការថែទាំ
- ផ្តល់ការថែទាំឯកត្តសមស្រប
- បង្កើនការត្រួតពិនិត្យជំងឺឆ្លង
- រចនាសម្ព័ន្ធគិលានុបដ្ឋាក-យិកា និង ឆ្មបដើម្បីចាត់ចែងការងារថែទាំឱ្យបានល្អប្រសើរ ។

គោលនយោបាយនេះនឹងប្រើប្រាស់សំរាប់ការងារថែទាំជំងឺ ។ គឺជាគោលនយោបាយដែល អាចអនុវត្តសំរាប់ការងារថែទាំក្នុងពេលបច្ចុប្បន្ន និង ទៅអនាគតដែល និង ដាក់ឱ្យប្រើប្រាស់ដោយ ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

## I. គោលនយោបាយៈ

### ១. សេចក្តីផ្តើម :

ការអោយនិយមន័យទៅលើគោលនយោបាយនៃការថែទាំគឺ ចំពោះអ្នកដែលមានវិជ្ជាជីវៈពេទ្យ មានន័យថា :

*អ្វីដែលគេអនុវត្តត្រូវ :*

១- រៀបចំការណែនាំបង្ហាញពីរបៀបថែទាំដល់គិលានុបដ្ឋាក-យិកា និងឆ្មប

២- កំណត់គោលដៅអោយមានភាពសមស្របគ្នាជាមួយគោលនយោបាយ

៣-ជ្រើសរើសរកយុទ្ធសាស្ត្រ

៤-ដាក់ចុះនូវសកម្មភាពដែលធ្វើកន្លងមក ( actions )

គោលនយោបាយនេះ បានកត់ត្រានៅក្នុងគោលនយោបាយដែលបានបញ្ជាក់ជាទូទៅតាមមន្ទីរពេទ្យដោយសង្កត់ធ្ងន់លើគោលនយោបាយសុខាភិបាល ។

នៅប្រទេសកម្ពុជា មតិនៃការងារថែទាំនេះបានចាប់ផ្តើមនៅឆ្នាំ ២០០១ និងត្រូវបានអនុញ្ញាតអោយប្រធានថែទាំជំងឺដែលនៅតាមមជ្ឈមណ្ឌល ឬមន្ទីរពេទ្យជាតិ និងមន្ទីរពេទ្យបង្អែកខេត្ត-ក្រុងបញ្ចេញគោលគំនិត ដែលជាអាទិភាព និងបិទប្រកាសផ្សព្វផ្សាយពីទិសដៅប្រចាំឆ្នាំ ដល់ក្រុមការងាររបស់ពួកគេ ។ការត្រិះរិះពិចារណានេះបានបង្កើតឡើងដោយការិយាល័យថែទាំគិលានុបដ្ឋាក-យិកា និងឆ្មបនៃនាយកដ្ឋានមន្ទីរពេទ្យ ក្រសួងសុខាភិបាលសហការជាមួយនិងគណៈកម្មការថែទាំជំងឺនៅភ្នំពេញ ហើយគោលនយោបាយទី២នេះត្រូវអនុញ្ញាត អោយដាក់ចូលនៅក្នុងក្របខ័ណ្ឌនៃការថែទាំជំងឺ និងដល់ក្រុមការងារទាំងឡាយ ដើម្បីបង្កើន គុណភាពថែទាំជំងឺក្នុងរយៈពេលឆ្នាំ ២០០៤-២០០៨ ។

### ២. និយមន័យនៃការថែទាំជំងឺ :

តាមទស្សនវិជ្ជានៃការថែទាំជំងឺ របស់គិលានុបដ្ឋាក-យិកា និងឆ្មបមានកត្តា៤សំខាន់គឺ :

*២/១. មនុស្ស :*

គឺជាសភាវៈមានជីវិត ដែលរស់នៅលើផែនដី ហើយមានសតិសម្បជញ្ញៈ ចេះគិតគូរ ត្រិះរិះពិចារណាដឹងខុសត្រូវ ។

*២/២. សុខភាព :* ជាសុខមាលភាពដ៏ពេញលេញទាំងផ្លូវកាយ និងផ្លូវចិត្ត ផ្លូវសង្គម មិនគ្រាន់ត្រឹមតែគ្មាន ពិការភាពប៉ុណ្ណោះទេ ។

*២/៣. ជំងឺ :*

គឺជាភាពគ្មានផាសុខភាពទាំងផ្លូវកាយ ផ្លូវចិត្ត និងផ្លូវសង្គម ។

*២/៤.ការថែទាំ :*

ជាពិធីសាស្ត្រមួយដែលធ្វើអោយគិលានុបដ្ឋាក-យិកា/ឆ្មប ផ្តល់សេវាថែទាំដើម្បីភាពសុខស្រួលទាំងផ្លូវកាយផ្លូវចិត្តដល់អ្នកជំងឺ ដូចជា :

-បន្ថយការឈឺចាប់

-លើកកំពស់សុខភាព

-អនុវត្តលើការការពារជំងឺទាំងឡាយ និងអប់រំសុខភាព ។

## II. **កម្មវត្ថុនៃគោលនយោបាយ:**

*បង្កើនគុណភាពនៃការថែទាំជំងឺ*

*១- អនុញ្ញាតដល់ប្រធានគិលានុបដ្ឋាក-យិកា /ឆ្មប និងនាយអគារអោយមានការទទួលខុសត្រូវចំពោះគុណភាពនៃការថែទាំជំងឺ ។*

*សកម្មភាព និងការរៀបចំចាត់ចែងដោយភាពអង់អាចចំពោះវិជ្ជាជីវៈមានដូចតទៅ :*

- បង្កើតអោយមានគណៈកម្មការថែទាំថ្នាក់ជាតិ និងថ្នាក់ភូមិភាគ
- ទស្សនកិច្ចតាមមជ្ឈមណ្ឌល មន្ទីរពេទ្យជាតិ និង មន្ទីរពេទ្យបង្អែក ដើម្បីប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមក។
- ការទំនាក់ទំនងក្នុងការបណ្តុះបណ្តាលដែលបានធ្វើ និងគម្រោងផែនការដែលកំពុងអនុវត្ត
- ធ្វើសិក្ខាសាលាប្រចាំឆ្នាំ
- ការផ្សព្វផ្សាយព្រឹត្តិប័ត្រពត៌មាន
- ការអភិវឌ្ឍន៍សកម្មភាពបណ្តុះបណ្តាល ។

*២ - អភិវឌ្ឍការអនុវត្តន៍ដែលមានគុណភាពគ្រប់គ្រាន់ចំពោះការថែទាំជំងឺ*

*សកម្មភាព :*

- ការរៀបចំពិធីសារ

- ការផ្សព្វផ្សាយ ការផ្លាស់ប្តូរ ការប្រព្រឹត្តតាមទ្រឹស្តី
- ការវាយតំលៃដល់ការអនុវត្តន៍
- ការដាក់ចុះនូវការងារថែទាំដោយសំអាងទៅលើក្បួនខ្នាត ។

*៣ - ជួយគាំទ្រសំណូមពររបស់ប្រធានផ្នែកថែទាំជំងឺ*

- ការធ្វើអោយមជ្ឈមណ្ឌល ឬមន្ទីរពេទ្យមានភាពប្រសើរឡើងខាងផ្នែកអនាម័យ
- ការផ្តល់សំភារៈបរិក្ខារ

*សកម្មភាព :*

- ទស្សនកិច្ចជាទៀងទាត់នៅតាមមជ្ឈមណ្ឌលឬមន្ទីរពេទ្យបង្អែកផ្សេងៗ
- ដំណើរការដោយនៅជិតប្រធានមជ្ឈមណ្ឌល ឬប្រធានមន្ទីរពេទ្យ
- ផ្តល់ពត៌មានទៅក្រសួងសុខាភិបាល (នាយកដ្ឋានមន្ទីរពេទ្យ)

## III. គោលនយោបាយប្រតិបត្តិ:

*ក-ផ្តល់ការថែទាំឱ្យបានសមស្រប*

*១ -ធ្វើអោយងាយស្រួលក្នុងការត្រិះរិះក្នុងវង្វង់ការងារថែទាំដោយទទួលខុសត្រូវលើអ្នកជំងឺមួយចំនួនចំពោះគិលានុបដ្ឋាក-យិកា និង ឆ្មបម្នាក់* **(Globalisation des Soins)**

*សកម្មភាព :*

- ការពន្យល់ និងការផ្សព្វផ្សាយស្តីពីការថែទាំជំងឺតាមរបៀបថ្មី (Nursing Process)
- ការរៀបចំសេវាថែទាំជំងឺលើមធ្យោបាយធនធានមនុស្ស និងសំភារៈបរិក្ខារ
- ពិចារណាទៅលើពេលវេលាធ្វើការ និងការថែទាំជាក្រុមតាមផ្នែកតូចៗនិមួយៗ (Soins en série Ex. Piqûres, Pansement, Prélèvement...) ។

*២ - ជួយរៀបចំសំណុំលិខិតអ្នកជំងឺអោយបានសមស្របនៅក្នុងមជ្ឈមណ្ឌល និងមន្ទីរពេទ្យនិមួយៗ*

*សកម្មភាព :*

- ជំរឿនសំណុំលិខិតអ្នកជំងឺដែលមាន អោយបានត្រឹមត្រូវ

- ការវាយតំលៃ ។

៣ - ជួយរៀបចំអោយអ្នកជំងឺ និងក្រុមគ្រួសារមានការចូលរួមចំណែកក្នុងការថែទាំ

សកម្មភាព :

- ផ្សព្វផ្សាយពតិមានដល់អ្នកជំងឺ និងក្រុមគ្រួសារអំពីការថែទាំដែលបានផ្តល់អោយ និងរបៀបរស់នៅក្នុងមន្ទីរពេទ្យ
- រៀបចំអោយមានវិន័យផ្ទៃក្នុង។ការអនុញ្ញាតអោយ អ្នកកំដរឬក្រុមគ្រួសារចូលសាកសួរសុខទុក្ខអ្នកជំងឺ ។

៤ - ប្តូរការយល់ដឹង និងផ្តល់ពតិមានទៅវិញទៅមកដែលទាក់ទងនឹងអ្នកជំងឺ

សកម្មភាព :

- បង្កើតអោយមានការផ្ទេរជំងឺដល់ក្រុមវិន័យការងារអោយបានដូចគ្នា
- រៀបចំការបញ្ជូនសំណុំឯកសាររបស់អ្នកជំងឺ នៅក្នុងមជ្ឈមណ្ឌល ឬក្នុងមន្ទីរពេទ្យ

ខ. បង្កើនការត្រួតពិនិត្យជំងឺឆ្លង

១ - លើកកំពស់អនាម័យ និង ការកំចាត់មេរោគនៅក្នុងមន្ទីរពេទ្យនិមួយ។

សកម្មភាព :

រៀបចំក្រុមថែរក្សាអនាម័យ និងឧបករណ៍ផ្សេង។តាមអគារ និងមជ្ឈមណ្ឌល ឬមន្ទីរពេទ្យ

- តែងតាំងនាយអគារ ឬគិលានុបដ្ឋាក-យិកា និងឆ្មបផ្នែកអនាម័យ
- បង្កើតគណៈកម្មការអនាម័យ
- ធ្វើការវាយតំលៃ ។

២ - ចល័តក្រុមការងារអោយយល់ដឹងពីអនាម័យ

សកម្មភាព :

- ផ្សព្វផ្សាយពីការអនុវត្តន៍ដ៏ល្អប្រពៃដែលទាក់ទងទៅនឹងអនាម័យ
- ការទំនាក់ទំនងស្តីអំពីពិធីសារដែលមាន
- ការបណ្តុះបណ្តាល
- ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមក ស្តីពីការងារនៅក្នុងមន្ទីរពេទ្យ
- យុទ្ធនាការធ្វើអោយមន្ទីរពេទ្យស្អាត

*៣ - ធ្វើអោយអ្នកជំងឺ និងក្រុមគ្រួសាររបស់គេមានការភ្ញាក់រលឹកពីអនាម័យ*

*សកម្មភាព :*

ស្រាវជ្រាវរកមធ្យោបាយទំនាក់ទំនងអោយបានសមរម្យ ឧទាហរណ៍ :

- ពន្យល់ណែនាំផ្ទាល់មាត់ និងតាមការសរសេរ
- បញ្ចាំងវីដេអូនៅក្នុងបន្ទប់រង់ចាំ ។

## IV.គោលនយោបាយរដ្ឋបាលៈ

*រចនាសម្ព័ន្ធសេវាគិលានុបដ្ឋាក-យិកា និងឆ្មប*

*១- ជួយចាត់ចែងបង្កើតសេវាគិលានុបដ្ឋាក-យិកា និង ឆ្មប នៅមន្ទីរពេទ្យក្នុងព្រះរាជាណាចក្រកម្ពុជា*

*សកម្មភាព :*

- តែងតាំងប្រធានគិលានុបដ្ឋាក-យិកា និងឆ្មប នៅក្នុងមន្ទីរពេទ្យជាតិនិមួយៗ និងមន្ទីរ ពេទ្យបង្អែក
- សុពលភាព និងការបិទប្រកាសស្តីអំពី រចនាសម្ព័ន្ធសេវាគិលានុបដ្ឋាក-យិកា និងឆ្មប ដោយប្រធានមន្ទីរពេទ្យ
- តែងតាំងគណៈកម្មការថែទាំជំងឺ នៅតាមមជ្ឈមណ្ឌល និងមន្ទីរពេទ្យនិមួយៗ

*២ - ធានានៅតាមមន្ទីរពេទ្យនានាមានភាពទំនាក់ទំនងគ្នាដោយសមស្របចំពោះការចាត់ចែង ការថែទាំជំងឺ*

*សកម្មភាព :*

- ការផ្សព្វផ្សាយពីតួនាទី ភារៈកិច្ចរបស់គិលានុបដ្ឋាក-យិកា និង ឆ្មប
- ការប្រតិបត្តិ និងការចាត់តាំងនៅក្នុងមន្ទីរពេទ្យនិមួយៗ គឺធ្វើទៅតាមគំរូស្តង់ដារតែមួយ (Standardisation) ។

*៣ - អោយតំលៃដល់ប្រធានថែទាំជំងឺ និងនាយអគារ*

*សកម្មភាព :*

- រៀបចំការបណ្តុះបណ្តាលពិសេស
- រៀបចំការប្រជុំជាមួយ :
  - -គណៈកម្មាធិការមន្ទីរពេទ្យ
  - -គ្រូពេទ្យ
  - -នាយអគារ
  - -ក្រុមការងារ (មានបុគ្គលិកថែរក្សាអចលនះវត្ថុ...)
  - -ផ្នែកគ្លីនិក និងក្រុមបច្ចេកទេស
- ការទទួលស្គាល់ពីមុខងាររបស់បុគ្គលិកនៅក្នុងមន្ទីរពេទ្យនិមួយៗ (បំពេញការងារជាក់លាក់តាមក្របខ័ណ្ឌ)
- ការចូលរួមក្នុងការបង្កើតលក្ខន្តិកៈក្បួនច្បាប់នៅថ្នាក់ក្រសួង ។

# V. ឧបសម្ព័ន្ធ

# បង្កើនគុណភាពនៃការថែទាំ

## ទិសដៅទី ១

*អនុញ្ញាតិដល់ប្រធានគិលានុបដ្ឋាក-យិកា និងឆ្មប និងនាយកអគារអោយមានការទទួលខុសត្រូវចំពោះគុណភាពនៃការថែទាំ*

*សកម្មភាព / ការរៀបចំចាត់ចែងដោយភាពអង់អាចចំពោះវិជ្ជាជីវៈមានដូចតទៅ :*

- បង្កើតអោយមានគណៈកម្មការថែទាំជំងឺថ្នាក់ជាតិ និងភូមិភាគ
- ទស្សនកិច្ចតាមមជ្ឈមណ្ឌលជាតិ / មន្ទីរពេទ្យជាតិ មន្ទីរពេទ្យបង្អែក ដើម្បីប្តូរបទពិសោធន៍ពីមន្ទីរពេទ្យមួយទៅមន្ទីរពេទ្យមួយ
- ទំនាក់ទំនងក្នុងការបណ្តុះបណ្តាលដែលបានធ្វើ និងគំរោងផែនការដែលកំពុងអនុវត្ត
- ធ្វើសិក្ខាសាលាប្រចាំឆ្នាំ
- ការផ្សព្វផ្សាយព្រឹត្តិប័ត្រពតិមាន
- ការផ្សព្វផ្សាយសេចក្តីប្រកាសស្តីពីការកំណត់តួនាទីភារកិច្ចរបស់ គិលានុបដ្ឋាក-យិកា-តួនាទីឆ្មប
- ការអភិវឌ្ឍន៍សកម្មភាពនៃការបណ្តុះបណ្តាល

## ទិសដៅទី២

*អភិវឌ្ឍដល់ការអនុវត្តន៏ដែលមានគុណភាពគ្រប់គ្រាន់ចំពោះការថែទាំជំងឺ*

*សកម្មភាព :*

- ការរៀបចំពិធីសារ
- ការផ្សព្វផ្សាយ ការផ្លាស់ ប្តូរ ការប្រព្រឹត្តតាមទ្រឹស្តី
- ការវាយតំលៃដល់ការអនុវត្តន៏
- ការដាក់ចុះនូវការងារថែទាំដោយសំអាងទៅលើក្បួនខ្នាត

## ទិសដៅទី ៣

*ជួយគាំទ្រសំណូមពររបស់ប្រធានថែទាំដំអី*

- ការធ្វើអោយមជ្ឈមណ្ឌល ឬមន្ទីរពេទ្យមានភាពប្រសើរឡើង
- ការបែងចែកសំភារៈទៅតាមតំរូវការនៃការថែទាំ

*សកម្មភាព :*

- ទស្សនកិច្ចជាទៀងទាត់នៅតាមមជ្ឈមណ្ឌល ឬតាមមន្ទីរពេទ្យ
- ដំណើរការដោយនៅជិតប្រធានមជ្ឈមណ្ឌល ឬមន្ទីរពេទ្យ
- ផ្តល់ពតិមានទៅក្រសួងសុខាភិបាល

*មន្ទីរពេទ្យ ..........................*

*កាលបរិច្ឆេទ .......................*

ការបណ្តុះបណ្តាល ឆ្នាំ ២០០៥ / ២០០៦

សមិទ្ធិផលសំរេចបាន

ទិសដៅ ឆ្នាំ ២០០៥ – ២០០៨

*មន្ទីរពេទ្យ ..........................*

*កាលបរិច្ឆេទ .......................*

ពិធីសារដែលសំរេចបាន ឆ្នាំ ២០០៤ / ២០០៥

ទិសដៅ ឆ្នាំ ២០០៥ – ២០០៨ ( ពិធីសារ )

មន្ទីរពេទ្យ ........................

កាលបរិច្ឆេទ ......................

ការរៀបចំទីកន្លែង ឆ្នាំ ២០០៤ / ២០០៥

គំរោងសំរាប់ ឆ្នាំ ២០០៥ - ២០០៨

សំភារៈដែលទទួលបាន ឆ្នាំ ២០០៤ - ២០០៥

គំរូវការផ្ទេកសំភារៈ ឆ្នាំ ២០០៥ - ២០០៨

# ការណែនាំបន្ថាញទី២

# ផ្តល់ការថែទាំដែលសមស្របតាមមន្ទីរពេទ្យនិមួយៗ

# (ដាក់អ្នកជំងឺនៅក្នុងមណ្ឌលថែទាំ)

### ទិសដៅទី ១

ធ្វើអោយងាយស្រួលក្នុងការថែទាំដោយយកចិត្តទុកដាក់ផ្តោតទៅលើអ្នកជំងឺ

សកម្មភាព :

- ពន្យល់ និង ផ្សព្វផ្សាយពីការថែទាំតាមរបៀបថ្មី (Soins Globaux)
- ការរៀបចំសេវាថែទាំជំងឺ ដោយសង្ឃឹមទៅលើមធ្យោបាយធនធានមនុស្ស និងសំភារៈបរិក្ខារផ្សេងៗ ( ពិចារណាទៅលើម៉ោងពេលធ្វើការ/ការងារជាក្រុម )

### ទិសដៅទី ២

ជួយរៀបចំអោយមានសំណុំឯកសារ ស្តីពីការថែទាំជំងឺមួយនៅក្នុងមជ្ឈមណ្ឌល ឬមន្ទីរពេទ្យនិមួយៗ

សកម្មភាព :

- ជំរឿនសំណុំឯកសារអ្នកជំងឺដែលមានអោយបានត្រឹមត្រូវ
- ការវាយតំលៃ

### ទិសដៅទី ៣

ជួយរៀបចំអ្នកជំងឺ និងក្រុមគ្រួសារអោយមានការចូលរួមចំណែកក្នុងការថែទាំ

សកម្មភាព :

- ផ្សព្វផ្សាយពត៌មានដល់អ្នកជំងឺ និងក្រុមគ្រួសារអំពី ការថែទាំដែល បានផ្តល់អោយ និងរបៀបរស់នៅក្នុងមន្ទីរពេទ្យ
- រៀបចំអោយមានវិន័យផ្ទៃក្នុងៗការអនុញ្ញាតអោយអ្នកកំដរឬក្រុមគ្រួសារចូលសួរសុខទុកអ្នកជំងឺ ។

**និសេវនី ៤ :**

*ប្តូរការយល់ដឹង និងផ្តល់ពត៌មានទៅវិញទៅមកដែលទាក់ទងនឹងអ្នកជំងឺ*

*សកម្មភាព :*

- ការរៀបចំបង្កើតអោយមានការឯកភាពគ្នាក្នុងការផ្ទេរអ្នកជំងឺដល់ក្រុមការងារទាំងអស់អោយបានដឹង
- រៀបចំបញ្ជូនសំណុំឯកសាររបស់អ្នកជំងឺរាល់ពេលដែលអ្នកជំងឺផ្លាស់ប្តូរទៅតាមផ្នែកនិមួយៗ ។

*មន្ទីរពេទ្យ ..........................*

*កាលបរិច្ឆេទ ......................*

*ការរៀបចំចាត់ចែងការងារថែទាំជំងឺ :*

- ពេលថ្មីៗនេះ

- ទិសដៅ ឆ្នាំ ២០០៥ / ២០០៨

*សំណុំឯកសារអ្នកជំងឺ :*

- ធ្វើអោយមានសន្លឹកសំរាប់ការផ្ទេរជំងឺរបស់គិលានុបដ្ឋាក-យិកា

- ទិសដៅ ឆ្នាំ ២០០៥ - ២០០៨

មន្ទីរពេទ្យ ..........................

កាលបរិច្ឆេទ .......................

*ការផ្សព្វផ្សាយពត៌មាន . ការអប់រំដល់គ្រួសារអ្នកជំងឺ :*

- សមិទ្ធិផលសំរេចបាន ឆ្នាំ ២០០៤ / ២០០៥

- ទិសដៅ ឆ្នាំ ២០០៥ / ២០០៨

*ការរៀបចំបង្កើតការផ្ទេរជំងឺ :*

- សមិទ្ធិផលសំរេចបាន ឆ្នាំ ២០០៤ / ២០០៥

- ទិសដៅ ឆ្នាំ ២០០៥ – ២០០៨

# ការណែនាំបច្ចេកទេសទី ៣

# បង្កើនការត្រួតពិនិត្យជំងឺឆ្លង

***ទិសដៅទី ១***

*លើកកំពស់អនាម័យ និងរក្សាភាពគ្មានមេរោគនៅក្នុងមន្ទីរពេទ្យនិមួយៗ*

*សកម្មភាព:*

- រៀបចំអោយមានក្រុមថែទាំអចលនៈវត្ថុ
- តែងតាំងនាយអគារ ឬគិលានុបដ្ឋាក-យិកា / ឆ្មបក្នុងផ្នែកអនាម័យ
- បង្កើតគណៈកម្មការអនាម័យ
- ធ្វើការវាយតំលៃ ។

***ទិសដៅទី ២***

*ចល័តក្រុមការងារ អោយយល់ដឹងពីការងារនៅជុំវិញអនាម័យ*

*សកម្មភាព :*

- ផ្សព្វផ្សាយពីការអនុវត្តន៍ដ៏ល្អប្រពៃដែលទាក់ទងទៅនឹងអនាម័យ
- ការទំនាក់ទំនងស្ដីអំពីពិធីសារដែលមាន
- ការបណ្ដុះបណ្ដាល
- ប្ដូរបទពិសោធន៍ ពីមន្ទីរពេទ្យមួយទៅមន្ទីរពេទ្យមួយ
- យុទ្ធនាការធ្វើអោយមន្ទីរពេទ្យស្អាត
- ធ្វើការអង្កេតស្ដីពីអនាម័យក្នុងមន្ទីរពេទ្យ

***ទិសដៅទី ៣***

*ធ្វើអោយអ្នកជំងឺ និងក្រុមគ្រួសារមានការភ្ញាក់រលឹកពីអនាម័យ*

*សកម្មភាព :*

- ស្រាវជ្រាវរកមធ្យោបាយទំនាក់ទំនងអោយបានសមស្រប

ឧទាហរណ៍ :

- ពន្យល់ណែនាំដោយផ្ទាល់មាត់ និងតាមការសរសេរបិទនៅជញ្ជាំង
- បញ្ចាំងវីដេអូនៅក្នុងបន្ទប់រង់ចាំ ។

*មន្ទីរពេទ្យ .........................*

*កាលបរិច្ឆេទ ......................*

*ការផ្ដើមឡើងពីសកម្មភាពទាំងឡាយដើម្បីអនាម័យ / ការសំអាតមេរោគ*

- សមិទ្ធិផលសំរេចបាន ឆ្នាំ ២០០៤ / ២០០៥

- កាលបរិច្ឆេទនូវសមិទ្ធិផលនៃការអង្កេតស្ដីពីអនាម័យ

- ទិសដៅ ឆ្នាំ ២០០៥ / ២០០៨

# ការណែនាំបង្ហាញទី ៤

## ធ្វើអោយមានរចនាសម្ព័ន្ធ
## សេវាគិលានុបដ្ឋាក-យិកា និង ឆ្មប
## ដើម្បីរៀបចំការងារថែទាំមួយដ៏ល្អប្រសើរ

### *ទិសដៅទី ១*

*ជួយចាត់ចែងបង្កើតសេវាគិលានុបដ្ឋាក-យិកា និងឆ្មបនៅក្នុងមជ្ឈមណ្ឌល ឬមន្ទីរពេទ្យនិមួយៗ ក្នុងព្រះរាជាណាចក្រកម្ពុជា*

*សកម្មភាព :*

- ការតែងតាំងប្រធានគិលានុបដ្ឋាក-យិកា និងឆ្មបនៅក្នុងមជ្ឈមណ្ឌល មន្ទីរពេទ្យជាតិ និង មន្ទីរពេទ្យបង្អែក។
- សុពលភាព និងការបិទប្រកាសស្ដីពីរចនាសម្ព័ន្ធសេវាគិលានុបដ្ឋាក-យិកា និងឆ្មប ដោយប្រធានមន្ទីរពេទ្យ
- តែងតាំងគណៈកម្មការថែទាំជំងឺនៅតាមមជ្ឈមណ្ឌល និងមន្ទីរពេទ្យនិមួយៗ ។

### *ទិសដៅទី ២*

*ធានានៅតាមមន្ទីរពេទ្យមានភាពទំនាក់ទំនងគ្នាដោយសមស្របចំពោះការចាត់ចែងការថែទាំជំងឺ*

*សកម្មភាព :*

- ផ្សព្វផ្សាយតួនាទីភារកិច្ចដែលបានរៀបចំឡើងដោយក្រសួងសុខាភិបាល
- ការប្រតិបត្តិ និងការចាត់តាំងនៅក្នុងមជ្ឈមណ្ឌល និងមន្ទីរពេទ្យនិមួយៗ (ធ្វើទៅតាមគំរូស្តង់ដារតែមួយ ) ។

### *ទិសដៅទី ៣*

*អោយតំលៃដល់មុខងារប្រធានថែទាំជំងឺ និងនាយអគារ*

*សកម្មភាព :*

- រៀបចំការបណ្តុះបណ្តាលពិសេស
- រៀបចំការប្រជុំជាមួយ :

- នាយអគារ
- គណៈកម្មាធិការមន្ទីរពេទ្យ
- គ្រូពេទ្យ
- ក្រុមការងារ ( មានបុគ្គលិកថែទាំអចលនៈវត្ថុ )
- ផ្នែកគ្លីនិក / បច្ចេកទេស ។

- ការទទួលស្គាល់ពីមុខងាររបស់បុគ្គលិកនៅក្នុងមជ្ឈមណ្ឌល និងមន្ទីរពេទ្យនិមួយៗ ( ការបំពេញការងារជាក់លាក់ទៅតាមក្របខ័ណ្ឌ )
- ការចូលរួមក្នុងការបង្កើតលក្ខន្តិកៈក្បួនច្បាប់នៅថ្នាក់ក្រសួង ។

*មន្ទីរពេទ្យ .........................*

*កាលបរិច្ឆេទ .......................*

រចនាសម្ព័ន្ធ

តួនាទីភារកិច្ចដែលមាន

ការរៀបចំប្រជុំ

ទិសដៅ ឆ្នាំ ២០០៥ / ២០០៨